ធនាគារជាតិ នៃ កម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ.....................................................

# សុន្ទរកថា
## លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងទិវាអបអរសាទរការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ លើកទី៣៦
### មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៦

**សូមគោរព ៖**

**- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ថ្ងៃនេះ តាងនាម ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយឥតឧបមា ដោយបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ទាំងអស់ ក្នុងទិវាអបអរសាទរការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ **លើកទី៣៦, ២០ មីនា ១៩៨០ - ២០ មីនា ២០១៦** ។ ទិវានេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងរំឭកខួបនៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ ព្រមទាំងដើម្បីបង្ហាញពីការគាំទ្រ និងលើកទឹកចិត្តឱ្យគ្រប់វិស័យទាំងអស់ បន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាតិរបស់យើង ក្នុងប្រតិបត្តិការទាំងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ខ្លួន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ខ្ញុំសូមថ្លែងអំណរគុណ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ទាំងអស់ ដែលបានឆ្លៀតពេលវេលាដ៏មានតម្លៃចូលរួមក្នុងទិវាប្រាក់រៀល នាពេលនេះ ដែលត្រូវជាថ្ងៃអាទិត្យថែមទៀត ។ សូមអរគុណជាពិសេសចំពោះសមាគមសហគ្រិនវ័យក្មេងកម្ពុជា ដែលបានសហការរៀបចំទិវានេះជាមួយធនាគារជាតិនៃកម្ពុជា ។

**- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនដោយសង្ខេបពីប្រវត្តិនៃការប្រើប្រាស់រូបិយវត្ថុនៅកម្ពុជាថា ៖ យោងតាមការស្រាវជ្រាវរបស់លោក Jean-Daniel Gardere ប្រវត្តិនៃការប្រើប្រាស់រូបិយវត្ថុនៅកម្ពុជាចាប់ផ្តើមឡើង ចាប់តាំងពីមានការបោះផ្សាយប្រាក់ស្លឹងនៅសតវត្សរ៍ទី១៦ ប៉ុន្តែការប្រើប្រាស់រូបិយវត្ថុជាតិនេះ មានលក្ខណៈជានិមិត្តរូបជាជាងលក្ខណៈទូលំទូលាយក្នុងសេដ្ឋកិច្ច ។ បន្ទាប់មក នៅសតវត្សរ៍ទី១៩ ក្រោមអាណាព្យាបាលបារាំង ធនាគារឥណ្ឌូចិនបានទទួលសិទ្ធិពិសេសក្នុងការបោះផ្សាយរូបិយវត្ថុក្នុងតំបន់ឥណ្ឌូចិន



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

នៅឆ្នាំ១៨៧៥ ។ ការប្រើប្រាស់កាសនិងក្រដាសប្រាក់បានចាប់ផ្តើមក្នុងសេដ្ឋកិច្ចចាប់ពីពេលនោះមក ។ រហូតដល់ឆ្នាំ១៩៤៨ អាណាព្យាបាលបារាំងបានធ្វើកំណែទម្រង់រូបិយវត្ថុក្នុងតំបន់ ដោយបានបង្កើតរដ្ឋសមាគមឥណ្ឌូចិន ដើម្បីផ្តល់សិទ្ធដល់ប្រទេសក្នុងតំបន់ឥណ្ឌូចិនចូលរួម ក្នុងការសម្រេចចិត្តច្រើនជាងមុនលើផ្នែករូបិយវត្ថុ ប៉ុន្តែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់បារាំង ។ តំបន់ឥណ្ឌូចិនត្រូវរង់ចាំរហូតដល់ឆ្នាំ១៩៥២ ដើម្បីមានវិទ្យាស្ថានបោះផ្សាយនៃរដ្ឋទាំងបីគឺ កម្ពុជា វៀតណាម និងឡាវ និងបានបោះផ្សាយរូបិយវត្ថុឥណ្ឌូចិនសម្រាប់ប្រើប្រាស់ក្នុងប្រទេសទាំងបី ។ ឈ្មោះឯកតារូបិយវត្ថុជាតិខ្មែរ "រៀល" ត្រូវបានចាប់បដិសន្ធិឡើងចាប់ពីពេលនោះមកជាមួយនឹងខ្នាតរូបិយវត្ថុពីរទៀត គឺដុងរបស់វៀតណាម និងគីបរបស់ឡាវនៅលើក្រដាសប្រាក់ឥណ្ឌូចិនតែមួយ ។ ក្រោយមក បន្ទាប់ពីទទួលបានឯករាជ្យពីបារាំង ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងនៅចុងឆ្នាំ១៩៥៤ និងបានបោះផ្សាយប្រាក់រៀលសម្រាប់ប្រើប្រាស់នៅក្នុងសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ១៩៥៥ ។

គួររំឭកថា នៅថ្ងៃនេះកាលពី ៣៦ ឆ្នាំមុន ប្រាក់រៀលត្រូវបានដាក់ឱ្យចរាចរឡើងវិញបន្ទាប់ពីធនាគារកណ្តាលត្រូវបានបង្កើតឡើងវិញនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ក្រោយថ្ងៃមហាជ័យជំនះ ៧ មករា ១៩៧៩ លើរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានលុបបំបាត់ការប្រើប្រាស់រូបិយវត្ថុ ទីផ្សារ និងរាល់ខឿនសេដ្ឋកិច្ចនិងសង្គម ។ លើសពីនេះ ការអូសបន្លាយនៃសង្គ្រាមស៊ីវិលជិត ៣០ ឆ្នាំ បានធ្វើឱ្យសាធារណជនបាត់បង់ជំនឿទុកចិត្តលើប្រាក់រៀល ។ ខ្ញុំពិតជាមានមោទនភាពដែលសង្កេតឃើញថា ជំនឿទុកចិត្តលើប្រាក់រៀលត្រូវបានពង្រឹងជាលំដាប់ ជាពិសេស ក្នុងរយៈពេលជាង ១៥ ឆ្នាំចុងក្រោយនេះ ពេលដែលកម្ពុជាទទួលបានសន្តិភាពពេញលេញ ១០០ ភាគរយ ។ ស្ថិរភាពនយោបាយ សុខសន្តិភាព សុវត្ថិភាពសង្គម និងស្ថិរភាពសេដ្ឋកិច្ច គឺជាកត្តាមូលដ្ឋានដែលបានញ៉ាំងឱ្យតម្រូវការប្រាក់រៀលកើនឡើង ស្របនឹងការអភិវឌ្ឍរីកចម្រើននៃវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ ។

ការប្រើប្រាស់ប្រាក់រៀលមានសារៈសំខាន់ណាស់ចំពោះសង្គម និងសេដ្ឋកិច្ចជាតិទាំងមូល ។ មុននឹងនិយាយពីសារៈសំខាន់របស់ប្រាក់រៀល ខ្ញុំក៏សូមរំឭកផងដែរពីបទ-ពិសោធន៍ ដែលប្រទេសយើងគ្មានរូបិយវត្ថុផ្ទាល់ខ្លួនដើម្បីប្រើប្រាស់កាលពីអតីតកាល ។ អវត្តមានរូបិយវត្ថុត្រូវបានមើលឃើញថា ជាកត្តាចម្បងមួយក្នុងចំណោមកត្តាសេដ្ឋកិច្ចនិងនយោបាយនានា ដែលបានរួមចំណែកក្នុងការធ្វើឱ្យប្រទេសយើងចុះដុនដាបពីស្ថានភាពនៃប្រទេសដែលបានអភិវឌ្ឍខ្លួនក្លាយទៅជាអាណាចក្រខ្មែរក្នុងសម័យអង្គរ ។ បទពិសោធន៍នេះបង្ហាញយ៉ាងច្បាស់ថា កម្ពុជាត្រូវតែរក្សានិងជំរុញការប្រើប្រាស់ប្រាក់រៀល ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិយើងប្រកបដោយចីរភាព ។

រូបិយវត្ថុជាតិមានសារៈសំខាន់ណាស់ ក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដោយសារតែតួនាទីចម្បងនៅក្នុងសេដ្ឋកិច្ចនិងសង្គម ។ ប្រាក់រៀលតំណាងឱ្យអត្តសញ្ញាណជាតិខ្មែរមួយក្នុងចំណោមអត្តសញ្ញាណនានា ដូចជា ទង់ជាតិ ភ្លេងជាតិ ប្រាង្គប្រាសាទអង្គរវត្ត ជាដើម ។ រូបភាពដែលរំលេចលើក្រដាសប្រាក់ ឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រនិងការរីកចម្រើនផ្ទាល់របស់សង្គមជាតិយើង ហើយការប្រើប្រាស់ប្រាក់រៀលតែមួយនឹងរំឭកនិងជំរុញទឹកចិត្តប្រជាជនខ្មែរគ្រប់រូបឱ្យកាន់តែមានស្មារតីជាតិនិយម និងសាមគ្គីភាពជាតិ ។ ក្នុងតួនាទីសេដ្ឋកិច្ច ប្រាក់រៀលពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយអត្រាប្តូរប្រាក់ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាបរិដ្ឋានអំណោយផលមិនអាចខ្វះបានក្នុងការអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ ។ នៅក្នុងវិស័យពាណិជ្ជកម្ម ការប្រើប្រាស់ប្រាក់រៀលតែមួយជួយកាត់បន្ថយចំណាយប្រតិបត្តិការ ដូចជាការប្តូរប្រាក់សម្រាប់ដោះដូរក្នុងស្រុក កាត់បន្ថយហានិភ័យពីការបាត់បង់ដោយសារការប្រែប្រួលអត្រាប្តូរប្រាក់ និងសម្រួលការកំណត់ថ្លៃដោះដូរតែមួយ ដែលធ្វើឱ្យការដោះដូរប្រព្រឹត្តទៅយ៉ាងងាយស្រួលនិងឆាប់រហ័ស ។ ការប្រើប្រាស់ប្រាក់រៀល រួមចំណែកជំរុញការវិនិយោគនិងបង្កើតការងារធ្វើ តាមរយៈឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុ លើការបន្ទាបអត្រាការប្រាក់ទីផ្សារ ដែលជាកត្តាកំណត់និន្នាការនៃកម្ចីសម្រាប់ការវិនិយោគនិងផលិតកម្ម ដែលមានផលវិជ្ជមានលើការបង្កើតការងារធ្វើ ។ ក្នុងផ្នែកហិរញ្ញវត្ថុ ការប្រើប្រាស់រូបិយប័ណ្ណបរទេស ប្រៀបដូចជា ការផ្តល់ប្រាក់កម្ចីដោយមិនមានការប្រាក់ដល់ធនាគារកណ្តាលបរទេស ដែលបោះផ្សាយរូបិយប័ណ្ណទាំងនោះដែរ ។ ដូច្នេះ ការប្រើប្រាស់ប្រាក់រៀល នឹងធ្វើឱ្យប្រទេសយើងទទួលបានប្រាក់ចំណូលពីការបោះពុម្ព និងស្រូបយកនូវរូបិយប័ណ្ណ ដើម្បីគរពូនជាទុនបម្រុង សម្រាប់ពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិនមកលើសេដ្ឋកិច្ចកម្ពុជា ។ ទាំងនេះ គ្រាន់តែជាសារៈសំខាន់មួយផ្នែកប៉ុណ្ណោះនៃការប្រើប្រាស់ប្រាក់រៀល នៅមានអត្ថប្រយោជន៍ដ៏ច្រើនទៀត ដែលជួយគាំទ្រសេដ្ឋកិច្ចរបស់យើងឱ្យអភិវឌ្ឍប្រកបដោយចីរភាព ។

**- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ខ្ញុំមានជំនឿថា កំណើនតម្រូវការប្រាក់រៀលរបស់សាធារណជន នារយៈពេលកន្លងមក និងការចូលរួមរបស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា នាពេលនេះ ជាសក្ខីភាពជាក់ស្បាន់ ចំពោះការរួមចំណែករបស់យើងទាំងអស់គ្នា ក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ដែលជាគោលនយោបាយចម្បងរបស់រាជរដ្ឋាភិបាល ។ ការខិតខំប្រឹងប្រែងបន្ថែមទៀតរបស់យើងទាំងអស់គ្នា នឹងផ្តល់ជាសហថាមភាពដ៏រឹងមាំដល់ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងសេដ្ឋកិច្ចជាតិ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល ក៏ដូចជា ធនាគារជាតិនៃកម្ពុជា នឹងបន្តគាំទ្រនិងលើកទឹកចិត្តដល់សាធារណជនទាំងអស់ក្នុងការ

ប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ខ្លួន ។ នាពេលឆាប់ៗខាងមុខនេះ យើងនឹងត្រូវដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធផ្ទេរប្រាក់រៀលថ្មីឈ្មោះថា FAST ដែលជាប្រព័ន្ធទូទាត់រាយ ដែលអាចឱ្យអតិថិជនទទួលបានប្រាក់ភ្លាមៗ ។ ឆ្លៀតក្នុងឱកាសនេះខ្ញុំសូមថ្លែងអំណរគុណ ចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ទាំងវិស័យសាធារណៈនិងវិស័យឯកជន ដែលបានខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់យើងនារយៈពេលកន្លងមក ។

មុននឹងបញ្ចប់ ខ្ញុំសូមលើកយកនូវពាក្យស្លោកមួយដែលគ្របដណ្តប់ជារួមពីអត្ថន័យនៃសារៈសំខាន់របស់ប្រាក់រៀលថា ៖ **"ប្រាក់រៀលតែមួយ លើកស្ទួយទីផ្សារ ផ្លែផ្កាសេដ្ឋកិច្ច"** ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា យើងទាំងអស់គ្នានឹងបន្តចូលរួមចំណែកបន្ថែមទៀតក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែច្រើនជាលំដាប់ ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧញ៉ា លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងទិវាប្រាក់រៀលរបស់យើងនាពេលនេះនិងសូមជូនពរ ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ**!